


## ការដើរកំសាន្តក្នុងព្រៃ

**វាអាចណែនាំបានចំពោះការមិនត្រូវទៅដើរកំសាន្តក្នុងព្រៃ នៅកំឡុង ថ្ងៃនានាដែលគ្រោះថ្នាក់ភ្លើងព្រៃកំពុងកើតមានឡើង តែបើអ្នកជាប់ខ្លួន នៅក្នុងព្រឹត្តិការណ៍ភ្លើងព្រៃមួយ អ្នកគួរ:**

- កុំ ព្យាយាមរត់ឆ្លេឆ្លាចេញពី ឬ រត់កន្លងអណ្តាតភ្លើង។
- រត់សំដៅទៅរកផ្លូវភ្លើងធម្មជាតិមួយ ឧ. ដងអូរ ដីឆ្ការព្រៃហើយ ឬ ថ្មផុសផុតពីដី។
- ស្ថិតនៅឲ្យឆ្ងាយពីដីទទួលដែលនៅតាមមុខនៃភ្លើងកំពុងឆេះ។
- កុំជ្រកនៅលើអាងទឹកដែលស្ថិតនៅលើដី។
- ពួនខ្លួនអ្នក ឬ ជ្រកនៅក្រោយរបស់រឹងមួយដែលមានដូចជា ផ្ទាំងថ្ម ដើម្បីការពារខ្លួនអ្នកពីកម្តៅដែលជះមក។

## ការបោះជំរុំ និង ផ្ទះឈើទូក

**មនុស្សម្នានៅថ្ងៃវិស្សមកាលសម្រាប់ការបោះជំរុំ និង ផ្ទះឈើទូក ត្រូវតែ ធានាឲ្យបានថាពួកគេមានការយល់ដឹងអំពីកម្រិត/លក្ខខ័ណ្ឌភ្លើងព្រៃនានានៅតាមមូលដ្ឋាន។**

បើការបោះជំរុំ ឬ ស្នាក់នៅឧទ្យានគេហចរមួយ ចូរសាកសួរមើលថាតើ តំបន់ជម្រៀសមួយសម្រាប់សុវត្ថិភាព ត្រូវបានគេរៀបចំហើយឬនៅ។ អគារបង្គន់មួយដែលធ្វើពីឥដ្ឋ ឬ កន្លែងទឹកផ្កាឈូក អាចជាជម្រើសដ៏ប្រសើរបំផុត។

ចូរមានការប្រុងប្រយ័ត្នខ្ពស់ ចំពោះការប្រើប្រាស់ម៉ាស៊ីនភ្លើង និង ធ្វើឲ្យប្រាកដថាអ្នកមានការយល់ដឹងអំពីកំហិត/លក្ខខ័ណ្ឌប្រើប្រាស់ភ្លើង ចំពោះភ្លើងព្រៃជាមួយនឹង BBQ។

បើកំពុងទៅមើលឧទ្យានជាតិមួយ ចូរសាកសួរក្រុមតម្រួតអំពីបញ្ហា ភ្លើងព្រៃនៅទីនោះ និង បទបញ្ជាចំពោះការធ្វើ BBQ ដោយសារវាអាចប្រែប្រួល។

ចំណុចនេះក៏អនុវត្តចំពោះក្រុមអ្នកប្រើប្រាស់ផ្ទះលើទូកផងដែរពេលកំពុងបង្កាត់ភ្លើងតាមបណ្តោយជម្រាលស្ទឹង/ទន្លេ។

## សុវត្ថិភាពពីភ្លើងព្រៃនៅថ្ងៃវិស្សមកាល

ភ្លើងព្រៃអាចកើតមានឡើង ដោយគ្មានការព្រមានប្រាប់ជាមុន និង អាចមានផលប៉ះពាល់ភ្លាមៗ ចំពោះទីកន្លែងវិស្សមកាលរបស់អ្នក។ ប្រសិនបើអ្នកកំពុងមានគម្រោងទៅវិស្សមកាល អ្នកចាំបាច់ត្រូវគិតអំពីសុវត្ថិភាពពីភ្លើងព្រៃ និង របៀបជៀសវាងគ្រោះថ្នាក់នានាដោយសារភ្លើងព្រៃ។

ខិតប័ណ្ណនេះ នឹងជួយឲ្យអ្នកត្រៀមរៀបចំខ្លួនបាន បើបញ្ហាភ្លើងព្រៃមួយប្រាកដជាកើតមានឡើងនៅតំបន់នោះ។

## មុនពេលដែលអ្នកចេញដំណើរ

- ពិនិត្យតំបន់ហាមឃាត់ និង កម្រិតគ្រោះថ្នាក់ដោយសារភ្លើងព្រៃ សម្រាប់តំបន់ទាំងឡាយណាដែលអ្នកនឹងត្រូវធ្វើដំណើរទៅ។
- ត្រូវមានការត្រៀមរៀបចំ ដើម្បីផ្លាស់ប្តូរកម្មវិធីធ្វើដំណើររបស់អ្នក នៅចំថ្ងៃក្តៅហួតហែង និង មានខ្យល់ ប្រយោជន៍ជៀសវាងកន្លែងនានាដែលភ្លើងព្រៃអាចនឹងកើតមានឡើងបាន។
- ត្រូតពិនិត្យមើលកំហិត ឬ លក្ខខ័ណ្ឌភ្លើងព្រៃទាំងឡាយណាដែលអាចនឹងមាន កម្លាំងខ្លាំងដោយរួមមាន បម្រាមភ្លើងព្រៃទាំងស្រុង។
- គិតពិចារណាលើការយកទៅធ្វើវនភោជន៍ (ពិកនិក) នូវចំណីអាហារ និង ភេសជ្ជៈដែលមិនចាំបាច់ត្រូវការចម្អិន ឬ កម្តៅ។
- ចូរធ្វើឲ្យប្រាកដថា អ្នក និង យានយន្តរបស់អ្នកមានការត្រៀមបម្រុង សម្រាប់គ្រោះអាសន្នមួយ។
- ប្រាប់ទៅមិត្តភក្តិ ឬ ក្រុមគ្រួសារ អំពីកន្លែងដែលអ្នកកំពុងទៅ ហើយប្រាប់ដំណឹង ពួកគេប្រសិនបើ កម្មវិធីធ្វើដំណើររបស់អ្នកប្រែប្រួលទៅតាមនោះ។

## ខណៈពេលដែលអ្នកកំពុងចាកចេញទៅឆ្ងាយ

- ជានិច្ចកាល ជៀសវាងការធ្វើដំណើរចូលទៅតំបន់នានាដែលមានភ្លើងព្រៃកំពុងតែ ឆេះ។
- ត្រូវប្រុងស្មារតីជាដរាប។ មិនត្រូវរំពឹងលើការព្រមានប្រាប់ជាផ្លូវការមុននោះទេ។
- ត្រូវយល់ដឹងអំពីកម្រិតគ្រោះថ្នាក់នៃភ្លើងប្រចាំថ្ងៃ ហើយរីករាយសកម្មភាពនានាដែលមានសុវត្ថិភាពពីភ្លើងព្រៃនៃបណ្តាថ្ងៃដែលមានគ្រោះថ្នាក់។
- ត្រូវដឹងថាឧទ្យានមួយចំនួន ត្រូវបានបិទនៅបណ្តាថ្ងៃមានគ្រោះថ្នាក់ភ្លើងព្រៃខ្ពស់ - អ្នកអាចនឹងទទួលបានការណែនាំឲ្យចាចេញពីកន្លែងបោះជំរុំរបស់អ្នក។
- បើអ្នកឃើញ ឬ ធុំក្លិនផ្សែង ចូរព្យាយាមជៀសចេញ បើមានភ្លើងព្រៃមួយនៅជិត ដែលអាចនឹងគម្រាមកំហែងដល់អាយុជីវិតអ្នក:
  វាវបើកប៉ុស្តិ៍វិទ្យុដែលផ្សាយអំពីគ្រោះអាសន្នដែលមានចុះនៅក្នុងខិតប័ណ្ណនេះ ឬ ហៅទៅទូរស័ព្ទភ្ជាប់គ្នា (Hotline) សម្រាប់ព័ត៌មានអំពីភ្លើងព្រៃដែលមានលេខ 1300 362 361 (TTY 133 677)។

**ដើម្បីរាយការណ៍អំពីបញ្ហាអគ្គីភ័យ សូមហៅទូរស័ព្ទទៅលេខ 000 - សម្រាប់ការព្រមានប្រាប់ជាមុន និង សញ្ញាអំពីគ្រោះអាសន្ននានា វាវប៉ុស្តិ៍វិទ្យុមួយក្នុងចំណោមដៃគូផ្សាយអំពីបញ្ហាគ្រោះអាសន្នរបស់យើងខ្ញុំ**

បណ្តាដៃគូ(ស្ថានីយ៍)ផ្សាយអំពីគ្រោះអាសន្ននៅប្រទេសអូស្ត្រាលីភាគខាងត្បូង (SAEBP): **វិទ្យុ ABC តាមមូលដ្ឋាន, វិទ្យុ** FIVEaa, **ទូរទស្សន៍** Sky News, **ទូរទស្សន៍** WIN, **វិទ្យុផ្សាយពាណិជ្ជកម្មអូស្ត្រាលី**

**ប្រេកង់វិទ្យុនានានៅអូស្ត្រាលីភាគខាងត្បូង**

| | | |
|---|---|---|
| Adelaide | 891 ABC Adelaide | 891 AM |
| Adelaide | Cruise 1323 | 1323 AM |
| Adelaide | FIVEaa | 1395 AM |
| Adelaide | Nova 91.9 | 91.9 FM |
| Adelaide | Mix 102.3 | 102.3 FM |
| Adelaide | Triple M | 104.7 FM |
| Adelaide | SA FM | 107.1 FM |
| Andamooka | ABC North & West | 105.9 FM |
| Ceduna | Flow FM | 106.1 FM |
| Clare/Mid North | Flow FM | 107.5 FM |
| Coober Pedy | ABC North & West | 106.1 FM |
| Coober Pedy | Flow FM | 99.7 FM |
| Cook | ABC North & West | 107.7 FM |
| Coonalpyn | Flow FM | 97.7 FM |
| Glendambo | ABC North & West | 106.1 FM |
| Kapunda/Barossa | Flow FM | 99.5 FM |
| Kingscote | Flow FM | 95.5 FM |
| Kingston SE | Flow FM | 107.3 FM |
| Leigh Creek Coalfield | ABC North & West | 99.3 FM |
| Leigh Creek South | ABC North & West | 1602 AM |
| Maitland | Flow FM | 90.9 FM |
| Marree | ABC North & West | 105.7 FM |
| Minlaton | Flow FM | 98.9 FM |
| Mintabie | ABC North & West | 88.7 FM |
| Mt Barker | Power FM | 100.3 FM |
| Mt Gambier | 5SE | 963 AM |
| Mt Gambier | Star FM | 96.1 FM |
| Murray Bridge | 5MU | 1125 AM |
| Murray Bridge | Power FM | 98.7 FM |
| Naracoorte | ABC South East | 1161 AM |
| Naracoorte | Star FM | 100.9 FM |
| North Mt Gambier | ABC South East | 1476 AM |
| Oodnadatta | ABC North & West | 95.3 FM |
| Padthaway East | Flow FM | 100.3 FM |
| Pinnaroo | Flow FM | 96.5 FM |
| Port Augusta | 5AU | 1242 AM |
| Port Lincoln | 5CC | 765 AM |
| Port Lincoln | ABC Eyre Peninsula | 1485 AM |
| Port Lincoln | Magic FM | 89.9 FM |
| Port Pirie | ABC North & West | 639 AM |
| Prominent Hill | Flow FM | 91.3 FM |
| Riverland | 5RM | 801 AM |
| Riverland | ABC Riverland | 1062 AM |
| Riverland | Magic FM 93.1 | 93.1 FM |
| Roxby Downs | Flow FM | 97.9 FM |
| Roxby Downs | ABC North & West | 102.7 FM |
| Streaky Bay | ABC Eyre Peninsula | 693 AM |
| Streaky Bay | Flow FM | 99.3 FM |
| Victor Harbor | Power FM | 99.7 FM |
| Woomera | ABC North & West | 1584 AM |
| Woomera | Flow FM | 101.7 FM |
| Wudinna | Flow FM | 106.9 FM |
| Yalata | ABC North & West | 105.9 FM |

ទូរសព្ទ័ភ្ជាប់គ្នាអំពីព័ត៌មានភ្លើងព្រៃដែលមានលេខ
**1300 362 361 (TTY 133 677)**
ឬ មើល**www.cfs.sa.gov.au**

WDM22817_2010-2011

**ត្រៀមខ្លួនទុក.អនុវត្ត.រួចជីវិត.**

HOLIDAY SAFETY AND SURVIVAL

Khmer

# សុវត្ថិភាពថ្ងៃវិស្សមកាល និង គត្តរជីវិត (ការរួចជីវិត)

នៅកំឡុងរដូវមានភ្លើងព្រៃ



ទូរសព្ទ័ភ្ជាប់គ្នាអំពីព័ត៌មានភ្លើងព្រៃ

**1300 362 361 (TTY 133 677)**

www.cfs.sa.gov.au

Government of South Australia

**PREPARE. ACT. SURVIVE.**

BUSHFIRE READY

# ការស្ថិតនៅមានសុវត្ថិភាពអំពីភ្លើងព្រៃនៅបណ្តាថ្ងៃវិស្សមកាល

**ការធ្វើដំណើរនៅតាមជនបទ ក្នុងកំឡុងរដូវមានភ្លើងព្រៃ អាចធ្វើឱ្យអ្នក មានអន្តរាយបាន។ ត្រូវដឹងអំពីសញ្ញាព្រមានប្រាប់នានា និង ស្វែងយល់នូវអ្វីដែលត្រូវធ្វើ ប្រយោជន៍រក្សាសុវត្ថិភាពខ្លួនអ្នកផ្ទាល់។**

## បណ្តាតំបន់មានបម្រាមអំពីភ្លើងព្រៃ

កំហិត/លក្ខខ័ណ្ឌភ្លើងព្រៃអនុវត្តនៅទូទាំងបណ្តាតំបន់ មានបម្រាមភ្លើងព្រៃទាំងអស់នៅអូស្រ្តាលីភាគខាងត្បូង - មានជាអាទិ៍: រាជធានី Adelaide - នៅកំឡុងរដូវមានគ្រោះថ្នាក់ភ្លើងព្រៃ។ វាមានសារៈសំខាន់ណាស់ ចំពោះការដឹងអំពីតំបន់មានបម្រាមភ្លើងព្រៃមួយដែលអ្នកកំពុងទៅលេង ប្រយោជន៍ដឹងបានថាតើបម្រាមភ្លើងព្រៃមួយ មានបច្ចុប្បន្នភាព និង ថាតើកំហិត/លក្ខខ័ណ្ឌ អនុវត្ត ឬ មានពាក់ព័ន្ធដែរឬយ៉ាងណា។

តើអ្នកដឹងទេថា អ្នកកំពុងស្ថិតនៅក្នុងតំបន់ណាមួយដែលមានបម្រាមភ្លើងព្រៃ?

## បម្រាមដាច់ខាតអំពីភ្លើងព្រៃ

ផ្នែកភ្លើងព្រៃតាមជនបទ (CFS) អាចនឹងប្រកាសបម្រាមដាច់ខាតអំពីភ្លើងព្រៃ (Total Fire Bans) នៅតាមតំបន់មួយចំនួន ឬ នៅទូទាំងរដ្ឋ នៅបណ្តាថ្ងៃដែលមានធាតុអាកាសមិនល្អ - ដែលមានដូចជា សីតុណ្ហភាពខ្ពស់ ខ្យល់ខ្លាំងពីខាងជើង និង កម្រិតសំណើមទាប - អាចនឹងបណ្តាលឲ្យមានភ្លើងឆេះនានាដែលមិនអាចនឹងត្រួតត្រា(ពន្លត់)បាន។ បណ្តាសកម្មភាពពិតប្រាកដដូចជា ប៊ីប៊ីឃ្យូ (BBQ) និង ការដុតភ្លើងបោះជំរុំនានាត្រូវបានហាមឃាត់នៅបណ្តាថ្ងៃទាំងនេះ។

តើអ្នកដឹងនូវអ្វីដែលអ្នកអាច និង មិនអាចធ្វើនៅថ្ងៃនេះទេ?

## កម្រិតគ្រោះថ្នាក់នៃភ្លើងព្រៃ

រៀងរាល់ថ្ងៃនៅកំឡុងរដូវមានគ្រោះថ្នាក់ភ្លើងព្រៃកើតមានឡើង ធាតុអាកាស និង កត្តាផ្សេងៗត្រូវបានគេប្រើដើម្បីគណនាកម្រិតគ្រោះថ្នាក់នៃភ្លើងព្រៃ។ កម្រិតទាំងនេះមិនមែនជាកត្តាទស្សទាយពីកម្រិត*ប្រហាក់ប្រហែល*ដែលភ្លើងព្រៃមួយត្រូវកើតមានឡើងនោះទេ តែជាកម្រិត*គ្រោះថ្នាក់*ដែលវាអាចនឹងកើងមានឡើងបាន ប្រសិនបើវា*ប្រាកដជាបាន*កើតមានឡើង។

# នៅបណ្តាថ្ងៃគ្រោះថ្នាក់ភ្លើងព្រៃមានកម្រិតខ្ពស់

នៅ បណ្តាថ្ងៃ ដែលមានកម្រិតខ្ពស់នៃគ្រោះថ្នាក់ភ្លើងព្រៃ ឬ បម្រាមភ្លើងព្រៃដាច់ខាត វាមានលក្ខណៈល្អប្រសើរបំផុត ចំពោះការការពន្យាពេលធ្វើដំណើរមួយចូលទៅក្នុងព្រៃ ដោយសារគ្រោះថ្នាក់នានានៃភ្លើងព្រៃដែលនឹងចាប់ផ្តើមឡើង និង រាលដាលយ៉ាងឆាប់រហ័សនោះ មានកម្រិតខ្ពស់ខ្លាំង។ ចូរគិតអំពីអ្វីដែលអ្នកនឹងត្រូវធ្វើនៅបណ្តាថ្ងៃទាំងនោះ ចូរប្រតិបត្តិតាមបម្រាមអំពីភ្លើងព្រៃ និង ជៀសវាងសកម្មភាពនានាដែលអាចនាំឲ្យអ្នកជាប់ខ្លួននៅកន្លែងនានាដែលអន្តរាយកម្រិតខ្ពស់។
ឧទាហរណ៍ មួយជំនួសឲ្យការដើរកំសាន្តក្នុងព្រៃ ទៅហែលទឹក ឬ មើល រមណីយដ្ឋាននានានៅតាមមូលដ្ឋាននៃតំបន់មានកម្រិតហានិភ័យភ្លើងព្រៃទាបនៃ Safer Settlement និង បរិវេណនានាដែលមានសុវត្ថិភាពជាង (មើលខាងក្រោម)។

# ឋានានុក្រមទីកន្លែងនានាដែលមានសុវត្ថិភាពពីភ្លើងព្រៃជាងនៅអូស្រ្តាលីភាគខាងត្បូង

ផ្នែកគ្រប់គ្រងភ្លើងព្រៃនៅតាមជនបទ (CFS) បានបង្កើតនូវឋានានុក្រមនៃទីកន្លែងនានាដែលអាចផ្តល់ទំនាក់ទំនងបញ្ហាសុវត្ថិភាពពីភ្លើងព្រៃបាន។ ព័ត៌មានពិស្តារជាងនេះគេអាចរកបាននៅលើវិបសាយរបស់ផ្នែកគ្រប់គ្រងភ្លើងព្រៃតាមជនបទ CFS: www.cfs.sa.gov.au

មានសុវត្ថិភាពខ្ពស់បំផុត ⟷ មានសុវត្ថិភាពទាប

| | | |
|---|---|---|
| **BUSHFIRE SAFER SETTLEMENT** | ខាងក្នុងតំបន់ជាយៗរាជធានី Adelaide | ដែលសមរម្យសម្រាប់ការប្រើប្រាស់នៅកំឡុងការព្យាករណ៍អំពីធាតុអាកាសទាក់ទងនឹងភ្លើងដែលមិនល្អ ឬ នៅកំឡុងពេលមានភ្លើងព្រៃ។ |
| **BUSHFIRE SAFER PRECINCT** | ដែលបានរៀបចំឡើងនៅក្រៅជាយៗក្រុង និង បណ្តាកន្លែងតាំងលំនៅដ្ឋានតាមជនបទ។ | ដែលសមរម្យសម្រាប់ការប្រើប្រាស់នៅកំឡុងការព្យាករណ៍អំពីធាតុអាកាសទាក់ទងនឹងភ្លើងដែលមិនល្អ ឬ នៅកំឡុងពេលមានភ្លើងព្រៃ។ អាចនឹងស្ថិតរងការវាយប្រហារដោយបញ្ចេញភ្លើង រងើកភ្លើង និង ផ្សែងរបស់ភ្លើងព្រៃ។ |
| **LAST RESORT REFUGE** | ត្រូវបានគ្រោងរៀបចំឡើងមានរាងពងក្រពើ និង សំណង់អគារនានានៅតាមតំបន់ជនបទ។ | មិនសមរម្យសម្រាប់ការជ្រកនៅរយៈពេលយូរ ហើយអាចនឹងផ្តល់នូវការការពារបានតិចតួចប៉ុណ្ណោះនៅកំឡុងពេលមានភ្លើងព្រៃ។ |

# នៅក្នុងព្រឹត្តិការណ៍នៃភ្លើងព្រៃមួយ

**រក្សាស្មារតិប្រុងប្រយ័ត្នចំពោះបណ្តាតំបន់ជុំវិញខ្លួនអ្នក និង អនុវត្តតាមដំបូន្មាន ឬ ការណែនាំនានាដែលផ្តល់ឱ្យដោយបុគ្គលិកផ្នែកគ្រប់គ្រងគ្រោះអាសន្ន ឬ តាមការផ្សាយអំពីគ្រោះអាសន្ន តាមវិទ្យុនៅមូលដ្ឋាន (សូមមើលទំព័រខាងក្រោយសម្រាប់ប្រេកង់នានា)។**

អនុញ្ញាតិឲ្យមនុស្សម្នាក់បានដឹងពីគម្រោងរបស់អ្នក និង របៀបត្រូវទាក់ទងអ្នក។

នៅកំឡុងពេលដែលមានភ្លើងព្រៃមួយកើតមានឡើង ពេលវេលាសំខាន់បំផុត សម្រាប់សុវត្ថិភាពផ្ទាល់ខ្លួន គឺកំឡុងពេល5 ទៅ 10 នាទី ដែលវាត្រូវប្រើសម្រាប់មុខអណ្តាតភ្លើងត្រូវផុតទៅ។

នៅពេលដែលមុខភ្លើងបានផុតទៅ របស់របរនានានឹងស្ថិតក្រោម ឬ រងការបំភាយកម្តៅប៉ះនឹងអណ្តាតភ្លើងប៉ះនឹងរងើកផ្កាភ្លើង ផ្សែង សម្លេងអ៊ូអរខ្លាំង ភាពងងឹត និង ការដាច់អគ្គិសនី។

# ការបំភាយកម្តៅ

**ការបំភាយកម្តៅ អាចសម្លាប់ជីវិតមនុស្សបាន។ ដើម្បីការពារខ្លួនអ្នក អ្នក ត្រូវគ្របខ្លួនស្លៀកពាក់ឱ្យបានត្រឹមត្រូវ និង រកកន្លែងជ្រកការពារខ្លួន។**

ផ្ទះ/អគាររឹងមាំៗ សម្លៀកបំពាក់ដែលសមស្រប អាចនឹងផ្តល់នូវរបាំងការពារបានពីការបំភាយកម្តៅបាន។ វាមិនអាចជ្រាបចូល តាមរយៈរបស់រឹងនានាបានទេ ដែលមានន័យថា ការការពារដ៏ប្រសើរបំផុតរបស់អ្នក គឺស្ថិតនៅក្នុងផ្ទះ ឬ អគារមួយដែលមានការរៀបចំបានត្រឹមត្រូវ ប្រសិនបើអ្នកមិនអាចចាកចេញពីកន្លែងនេះ មុនពេលដែលភ្លើងព្រៃឆាបចាប់ផ្តើមឆេះឡើងទេនោះ។

# សម្លៀកបំពាក់ការពារផ្ទាល់ខ្លួន

**គ្របដណ្តប់រាល់កន្លែងដែលមានស្បែកចំហ ដើម្បីការពារខ្លួនពីការបំភាយកម្តៅ។ ស្លៀកពាក់:**

- អាវដៃ និង ខោជើងវែងដែលធ្វើពីសរសៃទស្សន៍ធម្មជាតិ ( ឧទាហរណ៍ ទ្បែន ឬ កប្បាស)។
- មួកសំបុកហាមធំ និង ស្បែកជើងឃ្លុប ឬ ស្បែកជើងកវែងដែលរឹង។

# ការធ្វើដំណើរនៅតាមផ្លូវ

**ធ្វើឱ្យប្រាកដថា យានយន្តរបស់អ្នកមានការផ្គត់ផ្គង់យ៉ាងត្រឹមត្រូវ សម្រាប់ដំណើរដែលអ្នកកំពុងតែព្យាយាមធ្វើ។**

ដាក់ភួយសំឡី/ទ្បែនឲ្យបានច្រើន និង ការផ្គត់ផ្គង់ទឹកសាប នៅយានយន្តរបស់អ្នកក្នុងករណីដែលអ្នកត្រូវជាប់ខ្លួននៅក្នុងភ្លើងព្រៃមួយ។

បើអ្នកដឹងអំពីភ្លើងព្រៃនានា មុននឹងអ្នកចាកចេញពីផ្ទះ ចូររៀបចំកម្មវិធីមានជម្រើសផ្លូវមួយ និង មិនត្រូវធ្វើដំណើរទៅកាន់កន្លែងដែលមានរងនូវផលប៉ះពាល់នោះទេ។
បើអ្នកឆ្លងកាត់ផ្សែង ខណៈកំពុងធ្វើដំណើរនោះចូរបត់វាង ហើយត្រឡប់ក្រោយវិញ។
ស្តាប់វិទ្យុ ហើយសុំជំនួយតាមមូលដ្ឋាននោះ ឲ្យជួយរកផ្លូវទៅបានដោយសុវ

# បើអ្នកចាំបាច់ត្រូវការប្រើយានយន្តរបស់អ្នកជាជម្រកការពារខ្លួនពីភ្លើងព្រៃមួយនោះ ចូរ:

- **ស្វែងរកទីស្រឡះដែលឆ្ងាយពីពីគុម្ពោតព្រៃស្តុក និង អ្វីៗដែលអាចឆេះបាននៅលើដីដែលមានដូចជា មែក និង ស្លឹកឈើ។**
- ចតយានយន្តនៅខាងផ្លូវថ្នល់ប្រយោជន៍ជៀសវាងការបុកគ្នា ដោយបញ្ហាការមើលមិនឃើញ។
- បែរមុខយានយន្តឆ្ពោះទៅរកមុខភ្លើងដែលកំពុងមក។
- បើកភ្លើងហ្វា និង សញ្ញាភ្លើងភ្លើងសញ្ញាគ្រោះថ្នាក់។
- បិទបង្អួចកញ្ចក់ និង ទ្វារទាំងអស់ឲ្យបានជិតល្អ។
- ស្ថិតនៅក្នុងយានយន្តរបស់អ្នក – វាផ្តល់នូវការការពារយ៉ាងប្រសើរបំផុត ពីការជះ ឬ បំភាយកម្តៅ។
- បិទរាល់រន្ធខ្យល់ និង ម៉ាស៊ីនត្រជាក់។
- ពន្លត់ម៉ាស៊ីនយានយន្ត។
- ក្រាបចុះនៅក្រោមបង្អួចកញ្ចក់ឲ្យដល់បាតយានយន្ត និង ដណ្តប់ភួយសំឡី/ទ្បែន។
- ទទួលទានទឹក ដើម្បីកាត់បន្ថយចំពោះហានិភ័យនានាការខ្សោះជាតិទឹក។

# ពេលដែលមុខភ្លើងបានឆេះផុតទៅ

- ស្ថិតនៅក្នុងយានយន្តរបស់អ្នក រហូតមុខភ្លើងបានឆេះរាលផុតទៅ។
- ផុងប្រេង មិនប្រាកដថានឹងមិនផ្ទុះទេ។
- ផ្សែងកាន់តែខ្លាំងឡើង នៅក្នុងយានយន្តរបស់អ្នក ហើយចំហាយផ្សែងនឹងចេញវិញ។ ក្រាបចុះទៅនឹងផ្ទៃរាបនៃបាតយានយន្តតាមដែលដែលអាចធ្វើទៅបាន ដើម្បីកាត់បន្ថយសម្រូបផ្សែង និងខ្ទប់មាត់ ដោយក្រណាត់មានសំណើម (តែ មិនសើមជោកទេ)។
- កង់ និង គ្រឿងជ័រនៃតួយានយន្ត អាចនឹងឆេះទៅបាន។ ក្នុងក្នុងធ្ងន់ធ្ងរលើសពីនេះផ្នែកខាងក្នុងយានយន្ត អាចនឹងឆាបឆេះទៅបាន។
- ពេលដែលមុខភ្លើងឆេះ បានឆាបឆេះផុតទៅ ហើយកម្រិតសីតុណ្ហភាព បានធ្លាក់ចុះបន្តិចម្តងៗ ត្រូវចេញពីយានយន្ត (ចូរប្រុងប្រយ័ត្នបំផុត – ផ្នែកនានាខាងក្នុងនឹងកម្តៅខ្លាំងណាស់)។
- ចល័តទៅកន្លែងមួយដែលមានសុវត្ថិភាព ដូចជា ដីដែលបានឆេះហើយ។
- ជ្រកនៅដោយដណ្តប់ខ្លួន នឹងភួយទ្បែន/សំឡី បន្តការផឹកទឹក និង រង់ចាំការជួយ។

**ភ្លើងព្រៃនានាអាចគម្រាមកម្ហែងអាយុជីវិតបានភ្លាមៗ និង ដោយមិនព្រមានប្រាប់ជាមុន**

មើលសញ្ញាភ្លើងព្រៃពិសេសផ្សេង និង អណ្តាតភ្លើងចេះដឹងកម្រិតគ្រោះថ្នាក់ភ្លើងព្រៃនៅតាមតំបន់របស់អ្នក និង យល់អំពីលក្ខ័ណ្ឌនានានៅតាមមូលដ្ឋាន មានផែនការ និង ប្រអប់ប្រដាប់ប្រដាសម្រាប់ការសង្គ្រោះជីវិតរបស់អ្នកពីភ្លើងព្រៃ ហៅទូរស័ព្ទទៅលេខ 000 ដើម្បីរាយការណ៍អំពីអគ្គីភ័យ (ភ្លើងព្រៃ)មួយដើម្បីស្វះស្វែងរកព័ត៌មាន

- ស្តាប់វិទ្យុនៅតាមមូលដ្ឋាន
- ឆ្ពោះទៅវិបសាយ www.cfs.sa.gov.au
- ឬ ហៅទៅទូរសព្ទ័ភ្ជាប់គ្នាអំពីព័ត៌មានភ្លើងព្រៃដែលមានលេខ 1300 362 361 (TTY 133 677)

| កម្រិតគ្រោះថ្នាក់ | តើវាមានន័យយ៉ាងដូចម្តេច? | តើខ្ញុំគួរធ្វើអ្វីខ្លះ? |
|---|---|---|
| **CATASTROPHIC**<br>បម្រាម ដាច់ខាត អំពីភ្លើងព្រៃ | • ទាំងនេះគឺជាបណ្តាលក្ខខ័ណ្ឌដ៏អាក្រក់បំផុតចំពោះភ្លើងព្រៃ ឬ ភ្លើងវាលស្មៅ។<br>• បើភ្លើងព្រៃមួយចាប់ផ្តើមឡើង និង សន្ធប់ខ្លាំង វានឹងពិបាកខ្លាំងចំពោះការត្រួតត្រាវាបាន ហើយនឹងត្រូវចំណាយធនធានពន្លត់សំខាន់ៗ និង ធ្វើឲ្យវាស្ថិតក្នុងលក្ខខ័ណ្ឌត្រជាក់វិញដើម្បីពន្លត់វាបាន។<br>• ភ្លើងនឹងចាប់ផ្តើមឆេះទៅមុខដែលជាក្បាលភ្លើង ហើយបណ្តាលឲ្យឆេះរាលដាលយ៉ាងលឿន។ រងើកផ្កាភ្លើងនឹងកើតមានឡើងពីច្រើនទិស។<br>• ផ្ទះសម្បែងនានាមិនត្រូវបានគេគ្រោងសាងសង់ឡើងដើម្បីឲ្យធន់ទៅនឹងបញ្ហាភ្លើងនៅក្នុងលក្ខខ័ណ្ឌទាំងនេះទេ។<br>• ទីកន្លែងដែលមានសុវត្ថិភាពបំផុតដើម្បីជ្រកការពារខ្លួននោះ គឺចេញឆ្ងាយពីកន្លែងនានាដែលពោបដោយភ្លើងព្រៃ។ | អ្នកចាំបាច់ត្រូវធ្វើនៅពេលនេះ<br>•គិតរឿងរួចជីវិតរបស់អ្នកជាមុន ហើយចាកចេញពីកន្លែងនានាដែលពោបដោយភ្លើងព្រៃនៅពេលយប់ ឬ ព្រឹកព្រលឹម – នេះគឺជាជម្រើសសុវត្ថិភាពបំផុតរបស់អ្នក។<br>• ដោះខ្លួនឲ្យបានភ្លាមៗជាបន្ទាន់ – មិនត្រូវរង់ចាំមើលវានោះទេ<br>• ជៀសវាងកន្លែងនានាដែលមានព្រៃស្តុក គម្ពោតក្រាស ឬ វែងៗ ស្មៅងាប់ៗ<br>• ត្រៀមខ្លួន, យល់ដឹង និង អនុវត្តគម្រោងកម្មវិធី សម្រាប់:<br>- ពេលដែលអ្នកត្រូវចាកចេញ - កន្លែងដែលអ្នកត្រូវទៅ - អ្វីដែលអ្នកត្រូវធ្វើ បើអ្នកមិនអាចចាកចេញបាន<br>- របៀបដែលអ្នកនឹងត្រូវទៅដល់ទីនោះ - ពេលដែលអ្នកត្រូវត្រឡប់មកវិញ |
| **EXTREME**<br>បម្រាម ដាច់ខាត អំពីភ្លើងព្រៃ | • ភ្លើងព្រៃទាំងនេះ មានស្ថានភាពក្តៅ ស្ងួត និង ខ្យល់ខ្លាំងបំផុតចំពោះបញ្ហាភ្លើងឆេះគម្ពោតព្រៃ ឬ ស្មៅមួយនោះ។<br>• បើមានភ្លើងព្រៃមួយកើតមានឡើង ហើយឆេះសន្ធប់លើ វានឹងមិនអាចទស្សន៍ទាយទុកបាន ផ្លាស់ទីឲ្យបានលឿនបំផុត ហើយពិបាកខ្លាំងចំពោះក្រុមអ្នកពន្លត់ដើម្បីត្រួតត្រាវាបាន។<br>• ភ្លើងនឹងចាប់ផ្តើមឆេះ និង រាលដាលយ៉ាងលឿនជាទីបំផុត។ រងើកផ្កាភ្លើងអាចចេញមកពីច្រើនទិស។<br>• ផ្ទះសម្បែងនានាដែលមានការត្រៀមខ្លួនចំពោះកម្រិតភ្លើងព្រៃខ្ពស់ ត្រូវបានគេសាងសង់ឡើងសម្រាប់ការការពារកម្រិតនានានៃភ្លើងព្រៃ និង ទទួលបានការការពារបានយ៉ាងមុតមាំ អាចនឹងផ្តល់នូវសុវត្ថិភាពបាន។<br>• អ្នកត្រូវតែមានការត្រៀមខ្លួនទុកទាំងកម្លាំងកាយ និង កម្លាំងចិត្តដើម្បីការពារខ្លួននៅក្នុងបណ្តាលក្ខខ័ណ្ឌទាំងនេះ។<br>•ទីកន្លែងដែលមានសុវត្ថិភាពបំផុតដើម្បីជ្រកការពារខ្លួននោះ គឺចេញឆ្ងាយពីកន្លែងនានាដែលពោបដោយភ្លើងព្រៃ។ | អ្នកចាំបាច់ត្រូវត្រៀមខ្លួនជាស្រេចដើម្បីអនុវត្ត(គេចខ្លួន)<br>• ស្នាក់នៅតែក្នុងផ្ទះរបស់អ្នក បើអ្នកមានការត្រៀមខ្លួនចំពោះកម្រិតខ្ពស់បំផុតនៃភ្លើងព្រៃ។ នេះមានន័យថា ផ្ទះសម្បែងរបស់អ្នកចាំបាច់ត្រូវការទទួលបានការសាងសង់សម្រាប់ការកម្រិតនានានៃការការពារភ្លើងព្រៃ ឧ. ស្រយាបដំបូលបិទជិត គម្របលើផ្នែកខាងក្រៅនៃម៉ាស៊ីនត្រជាក់ ទ្វារកញ្ចក់ស៊ុមដែក ជាដើម។<br>• អ្នកត្រូវតែមានការត្រៀមរៀបចំខ្លួនទុកជាមុនឲ្យបានល្អ និង អាចការពារបានយ៉ាងសកម្មនូវផ្ទះសម្បែងរបស់អ្នក បើមានភ្លើងភ្លើងព្រៃ/អគ្គីភ័យមួយចាប់កើតមានឡើង។ នេះមានន័យថា អ្នកមានសម្ភារៈបរិក្ខារ និង ប្រភពធនធានាត្រឹមត្រូវដើម្បីឲ្យភ្លើងឆេះត្រឹមជុំវិញផ្ទះរបស់អ្នក ឧ. ការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ ប្រដាប់បូមប្រេងដែលដាក់តាមខ្លួនបាន ម៉ាស៊ីនភ្លើង សម្លៀកបំពាក់ការពារ ជាដើម។<br>• បើអ្នកមិនមានការត្រៀមខ្លួនចំពោះកម្រិតខ្ពស់បំផុតនៃភ្លើងទេនោះ ការគេចចេញពីកន្លែងនានាដែលពោបដោយភ្លើងព្រៃនោះ ឲ្យបានមុន ពេលថ្ងៃ គឺជាជម្រើសដ៏ប្រសើរបំផុតរបស់អ្នក។ |
| **SEVERE**<br>បម្រាម ដាច់ខាត អំពីភ្លើងព្រៃ | •ភ្លើងព្រៃទាំងនេះ មានស្ថានភាពក្តៅ ស្ងួត និង ខ្យល់ខ្លាំងបំផុតចំពោះបញ្ហាភ្លើងឆេះគម្ពោតព្រៃ ឬ ស្មៅមួយនោះ។<br>• បើមានភ្លើងព្រៃមួយកើតមានឡើង ហើយឆេះសន្ធប់លើ វានឹងមិនអាចទស្សន៍ទាយទុកបាន ផ្លាស់ទីឲ្យបានលឿនបំផុត ហើយពិបាកខ្លាំងចំពោះក្រុមអ្នកពន្លត់ដើម្បីត្រួតត្រាវាបាន។<br>• ផ្ទះសម្បែងដែលមានការត្រៀមរៀបចំបានត្រឹមត្រូវដែលទទួលបានការការពារបានយ៉ាងមុតមាំ អាចផ្តល់នូវសុវត្ថិភាពបានល្អ។<br>• អ្នកត្រូវតែមានការត្រៀមខ្លួនទុកទាំងកម្លាំងកាយ និង កម្លាំងចិត្តដើម្បីការពារខ្លួននៅក្នុងបណ្តាលក្ខខ័ណ្ឌទាំងនេះ។ | អ្នកចាំបាច់ត្រូវមានការយល់ដឹង<br>• ផ្ទះសម្បែងដែលមានការត្រៀមរៀបចំបានត្រឹមត្រូវដែលទទួលបានការការពារបានយ៉ាងមុតមាំ អាចផ្តល់នូវសុវត្ថិភាពបានល្អ។ នេះមានន័យថា អ្នកមានសម្ភារៈបរិក្ខារ និង ប្រភពធនធានាត្រឹមត្រូវដើម្បីឲ្យភ្លើងឆេះត្រឹមជុំវិញផ្ទះរបស់អ្នក ឧ. ការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ ប្រដាប់បូមប្រេងដែលដាក់តាមខ្លួនបាន ម៉ាស៊ីនភ្លើង សម្លៀកបំពាក់ការពារ ជាដើម។<br>• បើអ្នកមិនមានការត្រៀមខ្លួនទេនោះ ការគេចចេញពីកន្លែងនានាដែលពោបដោយភ្លើងព្រៃនោះ ឲ្យបានមុនពេលថ្ងៃ គឺជាជម្រើសដ៏ប្រសើរបំផុតរបស់អ្នក។ |
| **VERY HIGH**<br>**HIGH**<br>**LOW-MODERATE** | • បើមានភ្លើងព្រៃមួយកើតមានឡើង វាទំនងជាមានការគ្រប់គ្រងបាននៅក្នុងលក្ខខ័ណ្ឌទាំងនេះ ហើយផ្ទះសម្បែងរបស់អ្នកអាចផ្តល់នូវសុវត្ថិភាពបាន។<br>• ត្រូវយល់ដឹងអំពីរបៀបដែលភ្លើងព្រៃអាចចាប់ផ្តើមកើតមានឡើង និង កាត់បន្ថយអន្តរាយ។ | • ត្រួតពិនិត្យគម្រោងកម្មវិធីសម្រាប់ការសង្គ្រោះជីវិតពីភ្លើងព្រៃរបស់អ្នក។<br>• ត្រួតពិនិត្យតាមដានមើលលក្ខខ័ណ្ឌនានា។<br>• ចំណាត់ការអាចនឹងចាំបាច់ត្រូវមាន។<br>• ចាកចេញ បើចាំបាច់។ |